**Declassified to Public**
**12 June 2020**

លេខ: D348

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**Kingdom of Cambodia**
**Nation Religion King**

**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

---

| ឯកសារបកប្រែ |
| --- |
| TRANSLATION/TRADUCTION |
| ថ្ងៃ ខែ ឆ្នាំ (Date): 28-Apr-2017, 15:44 |
| CMS/CFO: Sann Rada |

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ៖ ០០៤/២/០៧-០៩-២០០៩-អ.វ.ត.ក-ក.ស.ច.ស**

ចំពោះមុខ ៖ **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ ៖ **ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧**

ភាសា ៖ **អង់គ្លេស & ខ្មែរ [អង់គ្លេស ភាសាដើម ]**

ចំណាត់ថ្នាក់ឯកសារ ៖ **សម្ងាត់**

---

# ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី

---

**ផ្ញើជូន ៖**

**សហព្រះរាជអាជ្ញា**

ជា លាង
Nicholas KOUMJIAN

**មេធាវីការពារក្តី អោ អាន**

មុំ លុជ្ស
Richard ROGERS
Göran SLUITER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ជេត វណ្ណលី
ហុង គឹមសួន
គីម ម៉េងឃី
ឡោ ជុនធី
សំ សុគង់
ស៊ិន ស៊ីវ៉ន
ទី ស្រីនណា
វ៉ែន ពៅ

Laure DESFORGES
Isabelle DURAND
Emmanuel JACOMY
Martine JACQUIN
Lyma NGUYEN
Nushin SARKARATI

## I. ប្រវត្តិនីតិវិធី និងពិភាក្សា

១. ករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត (“ស.ច.ស”) នៅក្នុងសំណុំរឿង ០០៤/២ បានចុះបញ្ជីនៅថ្ងៃទី ២២ ខែ កុម្ភៈ ឆ្នាំ ២០១៣ ថ្ងៃទី ៥ ខែ មេសា ឆ្នាំ ២០១៣ ថ្ងៃទី ២២ ខែ មករា ឆ្នាំ ២០១៥ ថ្ងៃទី ២១ ខែ តុលា ឆ្នាំ ២០១៥ និងថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១៧។

២. ចាប់តាំងពីបើកកិច្ចស៊ើបសួរសំណុំរឿង ០០៤/២ មក មនុស្សចំនួន ១៩២២ នាក់ បានដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿង ០០៤/២។ នៅក្នុងទម្រង់បែបបទអំពីជនរងគ្រោះ ដែលបានដាក់មកការិយាល័យសហចៅក្រមស៊ើបអង្កេតនៅក្នុងសំណុំរឿង ០០៤/២ មានអ្នកដាក់ពាក្យសុំចំនួន ១៨៥ នាក់ បានស្នើសុំ ស.ច.ស ចេញដីកាបង្គាប់ឲ្យមានវិធានការការពារ យោងតាមវិធានផ្ទៃក្នុង ២៩ (“សំណើសុំវិធានការការពារ”)[1]។

៣. នៅថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥ ខ្ញុំបានស្នើសុំ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ត្រូវធ្វើការវាយតម្លៃលើកាលៈទេសៈពាក់ព័ន្ធនឹងសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីចំនួន ២៥៤ នាក់នៅក្នុងសំណុំរឿង ០០៣ សំណុំរឿង ០០៤ សំណុំរឿង ០០៤/១ និងសំណុំរឿង ០០៤/២[2]។

៤. នៅថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៧ អង្គការមេធាវីគ្មានព្រំដែន( Défenses Sans Frontières) (DSF) បានជូនដំណឹង ក.ស.ច.ស ថា អ្នកដាក់ពាក្យសុំចំនួនពីរនាក់បានដកពាក្យសុំវិធានការការពារវិញហើយ[3]។

៥. នៅថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧ មេធាវីដើមបណ្តឹងរដ្ឋប្បវេណីទ្វី ស្រ៊ីនណា បានជូនដំណឹង ក.ស.ច.ស ថា ក្នុងចំណោមអ្នកដាក់ពាក្យសុំវិធានការការពារដែលជាកូនក្តីគាត់ មាន ១១ នាក់ បានសម្រេចដកសំណើសុំវិធានការការពារវិញ ២ នាក់បានស្លាប់ហើយ និង ៧ នាក់

---

[1] បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំវិធានការការពារ។

[2] សំណុំរឿង ០០៤/២ ឯកសារ D264 *អនុស្សរណៈពី ស.ច.ស.អ ផ្ញើជូនអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ស្តីពី“សំណើសុំជំនួយពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញទាក់ទងនឹងសំណើសុំវិធានការការពាររបស់ដើមបណ្តឹងរដ្ឋប្បវេណី”* ថ្ងៃទី ១៦ ខែ កញ្ញា ឆ្នាំ ២០១៥។

[3] *អ៊ីមែលពី DSF ផ្ញើជូន ក.ស.ច.ស* ថ្ងៃទី ៩ ខែ មករា ឆ្នាំ ២០១៧។

សុំរក្សាសំណើវិធានការការពារនៅដដែល។ គាត់ក៏បានដកសំណើសុំវិធានការការពារតាងនាមឲ្យអ្នកដាក់ពាក្យសុំចំនួន ៣ នាក់ដែលគាត់មិនអាចទាក់ទងបាន[4]។

៦. នៅថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧ មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ជេត វណ្ណលី បានជូនដំណឹងអង្គភាពគាំពារជនរងគ្រោះ និង ក.ស.ច.ស ថា អ្នកដាក់ពាក្យសុំវិធានការការពារម្នាក់ដែលជាកូនក្ដីគាត់ បានស្លាប់ហើយ[5]។

៧. អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានជួបជាមួយនឹងអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីសរុបចំនួន ១៧០ នាក់ រាប់បញ្ចូលទាំងអ្នកដាក់ពាក្យសុំវិធានការការពារចំនួន ១៣២ នាក់ ហើយបានផ្ដល់ជូនអ្នកទាំងនោះនូវព័ត៌មានអំពីកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក ព្រមទាំងលក្ខណៈ តួនាទី និងគោលបំណងនៃវិធានការការពារ[6]។ អង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក៏បានរាយការណ៍ថា មេធាវីដើមបណ្ដឹងរដ្ឋប្បវេណី បានជូនដំណឹងអង្គភាពនេះអំពីការដកសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំចំនួន ៩ នាក់ ហើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីចំនួន ១២ នាក់ រួមមានអ្នកដាក់ពាក្យសុំវិធានការការពារចំនួន ១១ នាក់ បានស្លាប់ហើយ[7]។

៨. នៅក្នុងការវាយតម្លៃរបស់ខ្លួន អង្គភាពគាំពារសាក្សី និងអ្នកជំនាញ បានបង្ហាញថា អ្នកដាក់ពាក្យសុំវិធានការការពារទាំង ១៣២ ដែលខ្លួនបានជួប បានដកសំណើសុំវិធានការការពារវិញ ហើយបានបង្ហាញទៀតថា ក្នុងករណីណាក៏ដោយ ការវាយតម្លៃរបស់អង្គភាពគាំពារសាក្សី

---

[4]សំណុំរឿង ០០៤/១ ឯកសារ D310.3 *ឧបសម្ព័ន្ធ គ៖ អ៊ីមែលពីមេធាវី ទី ស្រ៊ីនណា ផ្ញើជូន ក.ស.ច.ស* ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។ សំណុំរឿង ០០៤/១ ឯកសារ D310.4 *ឧបសម្ព័ន្ធ ឃ៖ ឯកសារភ្ជាប់ជាមួយនឹងអ៊ីមែលពីមេធាវី ទី ស្រ៊ីនណា ផ្ញើជូន ក.ស.ច.ស* ថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១៧។

[5]សំណុំរឿង ០០៤/១ ឯកសារ D310.5 *ឧបសម្ព័ន្ធ ង៖ អ៊ីមែលពីមេធាវី ជេត វណ្ណលី ផ្ញើជូនអង្គភាពគាំពារជនរងគ្រោះ និង ក.ស.ច.ស* ថ្ងៃទី ១ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[6]សំណុំរឿង ០០៤/១ ឯកសារ D310.2 *ឧបសម្ព័ន្ធ ខ៖ អនុស្សរណៈពីអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ផ្ញើជូន ស.ច.ស.អ ស្ដីពី“បច្ចុប្បន្នភាពអំពីសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី”* ថ្ងៃទី ២៣ ខែ កុម្ភៈ ឆ្នាំ ២០១៧។

[7]ដូចជើងទំព័រខាងលើ។

និងអ្នកជំនាញ បានធ្វើការសន្និដ្ឋានថា មិនចាំបាច់តម្រូវឲ្យមានវិធានការការពារសម្រាប់អ្នកទាំងនោះទេ[8]។

៩. ដោយពិនិត្យមើលការវាយតម្លៃរបស់អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងការប្រាស្រ័យទាក់ទងគ្នាតាមអ៊ីមែលជាមួយនឹង DSF មេធាវី ទ្រី ស្រ៊ីនណា និងមេធាវី ជេត វណ្ណលី ទើបខ្ញុំសន្និដ្ឋានថា សំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំចំនួន ១៤ នាក់ ដែលបានស្លាប់ហើយ និងអ្នកដាក់ពាក្យសុំវិធានការការពារចំនួន ១៤៦ នាក់ដែលបានដកសំណើសុំវិធានការការពារវិញ ត្រូវទុកជាមោឃៈ។

១០. អង្គភាពគាំពារសាក្សី និងអ្នកជំនាញ និងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចជួបអ្នកដាក់ពាក្យសុំចំនួន ២៥ នាក់ផ្សេងទៀតក្នុងចំណោមអ្នកដាក់ពាក្យសុំវិធានការការពារចំនួន ១៨៥ នាក់បានឡើយ។

១១. នៅថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧ ស.ច.ស បានបដិសេធសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំវិធានការការពារចំនួន ២៤ នាក់ នៅក្នុងសំណុំរឿង ០០៤/១[9]។ ការវាយតម្លៃរបស់ ស.ច.ស មានភ្ជាប់ជាឧបសម្ព័ន្ធនៅក្នុងដីកាសម្រេចនេះ[10]។

១២. ខ្ញុំបានធ្វើការវាយតម្លៃលើសំណើសុំវិធានការការពារនីមួយៗរបស់អ្នកដាក់ពាក្យសុំដែលនៅសេសសល់ ដោយផ្អែកលើព័ត៌មាននៅក្នុងទម្រង់បែបបទអំពីជនរងគ្រោះ។

១៣. ខ្ញុំយល់ឃើញថា សំណើសុំវិធានការការពារទាំងនេះមិនមានអំណះអំណាងទេ ហេតុនេះគួរត្រូវបដិសេធដោយផ្អែកលើមូលដ្ឋាននេះ[11]។

---

[8]ដូចជើងទំព័រខាងលើ។

[9]សំណុំរឿង ០០៤/១ ឯកសារ D310 *ដីកាសម្រេចលើសំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី* ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧។

[10]សំណុំរឿង ០០៤/១ ឯកសារ D310.7 *ឧបសម្ព័ន្ធ ធ៖ បញ្ជីឈ្មោះអ្នកដាក់ពាក្យសុំវិធានការការពារដែល ស.ច.ស បានវាយតម្លៃ* ថ្ងៃទី ២០ ខែ មីនា ឆ្នាំ ២០១៧។

[11]ឧបសម្ព័ន្ធ ៣៖ *អ្នកដាក់ពាក្យសុំវិធានការការពារដែល ស.ច.ស.អ បានវាយតម្លៃ*។

**តាមសំអាងហេតុខាងលើ ខ្ញុំ៖**

១៤. **បង្គាប់** ក្រឡាបញ្ជី ក.ស.ច.ស ត្រូវដាក់ចូលក្នុងសំណុំរឿង ០០៤/២ នូវឯកសារដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ១។

១៥. **ប្រកាស** ថា សំណើសុំវិធានការការពាររបស់អ្នកដាក់ពាក្យសុំដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ២ ត្រូវទុកជាមោឃៈ។

១៦. **បដិសេធ** សំណើសុំវិធានការការពារដែលនៅសេសសល់ទាំងអស់របស់អ្នកដាក់ពាក្យសុំដូចបានបង្ហាញនៅក្នុងឧបសម្ព័ន្ធ ៣។

ភ្នំពេញ ថ្ងៃទី ២៨ ខែ មេសា ឆ្នាំ ២០១៧

**ចៅក្រម Michael Bohlander**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d’instruction International**